Department of Labor

# ការិយាល័យអត្ថប្រយោជន៍ និងផ្នែកអនុវត្តប្រាក់ឈ្នួល

# ការកិបកេងប្រាក់ឈ្នួល

## តើអ្វីជាការកិបកេងប្រាក់ឈ្នួល?

ការកិបកេងប្រាក់ឈ្នួលគឺជាការរំលោភច្បាប់សហព័ន្ធ ច្បាប់រដ្ឋ និងច្បាប់ទីក្រុងហ្វីឡាដែលហ្វៀ (Philadelphia)។ ការកិបកេងប្រាក់ឈ្នួលនេះគឺជាការអនុវត្តខុសច្បាប់ដោយការមិនបើកប្រាក់ឈ្នួលជូនកម្មករសម្រាប់រាល់ការងាររបស់ពួកគេ។ ការកិបកេងប្រាក់ឈ្នួលនេះរួមមានការរំលោភបំពានច្បាប់ប្រាក់ឈ្នួលអប្បបរមា ការមិនបើកប្រាក់បន្ថែមម៉ោង ការបង្ខំកម្មករនិយោជិតឱ្យធ្វើការក្រៅម៉ោង ការយកផ្នែកណាមួយនៃប្រាក់ធីបរបស់កម្មករនិយោជិត និងផ្សេងៗទៀត។ ដោយមិនគិតពីសញ្ជាតិ ឬស្ថានភាពអន្តោប្រវេសន៍ ការកិបកេងប្រាក់ឈ្នួលត្រូវបានហាមឃាត់ដោយច្បាប់។

## តើប្រាក់ឈ្នួលអប្បបរមាក្នុងទីក្រុងហ្វីឡាដែលហ្វៀថ្លៃប៉ុន្មាន?

ប្រាក់ឈ្នួលអប្បបរមាក្នុងទីក្រុងហ្វីឡាដែលហ្វៀថ្លៃ $7.25 ដែលជាប្រាក់ឈ្នួលអប្បបរមារបស់សហព័ន្ធ។

## អ្វីទៅដែលហៅថាការងារក្រៅម៉ោង?

ប្រសិនបើអ្នកធ្វើការលើសពី 40 ម៉ោងក្នុងមួយសប្តាហ៍ និយោជករបស់អ្នកត្រូវបង់ប្រាក់ឈ្នួលយ៉ាងហោចណាស់ 1.5 ដងនៃអត្រាប្រាក់ឈ្នួលធម្មតារបស់អ្នកសម្រាប់ម៉ោងដែលធ្វើការលើសពី 40 ម៉ោង។

## តើខ្ញុំធ្វើដូចម្តេចប្រសិនបើខ្ញុំជឿថាខ្ញុំជាជនរងគ្រោះនៃការកិបកេងប្រាក់ឈ្នួល?

អ្នក ភ្នាក់ងារដែលមានការអនុញ្ញាត ឬសហជីពការងាររបស់អ្នកអាចដាក់ពាក្យបណ្តឹងជំនួសអ្នកបាន។ អ្នកអាចទទួលបានទម្រង់ពាក្យបណ្តឹងរបស់អ្នកដោយផ្ញើអ៊ីមែលទៅការិយាល័យការពារកម្មករតាមរយៈ wagetheft@phila.gov ។ បន្ទាប់មក អ្នកត្រូវតែបញ្ជូនវាតាមរយៈសំបុត្រ ឬអ៊ីមែល។ សូមសួរបុគ្គលិកអំពីរបៀបចូលប្រើសេវាភាសាឥតគិតថ្លៃដែលផ្តល់ជូនដោយទីក្រុងហ្វីឡាដែលហ្វៀ ឬទូរស័ព្ទទៅការិយាល័យការពារកម្មករតាមលេខ 215-686-0802។

## តើខ្ញុំដឹងថាខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការដាក់ពាក្យបណ្តឹងនៅទីក្រុងហ្វីឡាដែលហ្វៀដោយរបៀបណា?

1. និយោជករបស់អ្នកមានទីតាំងនៅក្នុងទីក្រុងហ្វីឡាដែលហ្វៀ។
2. អ្នកជឿថាប្រាក់ឈ្នួលរបស់អ្នកត្រូវបានកិបកេងក្នុងរយៈពេល 3 ឆ្នាំចុងក្រោយនេះ។
3. ចំនួនប្រាក់ឈ្នួលដែលលួចមានច្រើនជាង $100។

## តើមានអ្វីកើតឡើងបន្ទាប់ពីខ្ញុំដាក់ឯកសារពាក្យបណ្តឹងរួច?

មានការស៊ើបអង្កេតលើបណ្តឹងនីមួយៗដែលបានដាក់។ បុគ្គលិកម្នាក់មកពីការិយាល័យការពារកម្មករនឹងទាក់ទងអ្នកក្នុងរយៈពេល 15 ថ្ងៃធ្វើការ ដើម្បីណែនាំអ្នកក្នុងដំណើរការបណ្តឹងនេះ និងស្នើសុំព័ត៌មានបន្ថែមដែលអាចជួយដល់បណ្តឹងរបស់អ្នក។ ការិយាល័យការពារកម្មករនឹងដោះស្រាយរាល់អន្តរកម្មជាមួយនឹងនិយោជករបស់អ្នក។ អ្នកអាចត្រូវបានស្នើសុំឱ្យផ្តល់ច្បាប់ចម្លងនៃកាលវិភាគកំណត់ត្រាដែលសរសេរដោយដៃ បង្កាន់ដៃបើកប្រាក់ឈ្នួល (Paystubs) និងព័ត៌មានជំនួយណាមួយ។ សូមរៀបចំទម្រង់បែបបទទាំងនេះឱ្យរួចរាល់ រួចដាក់ជាមួយនឹងពាក្យបណ្តឹងរបស់អ្នក។ ប្រសិនបើអ្នកមិនមានទម្រង់ទាំងនេះ ឬមិនប្រាកដទេ សូមដាក់ពាក្យបណ្តឹងរបស់អ្នក ហើយការិយាល័យគាំពារកម្មករនឹងធ្វើការតាមដាន។

## តើខ្ញុំអាចត្រូវបានបណ្តេញចេញពីការងារដែរឬទេ?

ច្បាប់ហាមឃាត់រាល់ទម្រង់នៃការសងសឹកចំពោះនិយោជិតដែលដាក់ពាក្យបណ្តឹងប្រឆាំងអំពើកិបកេងប្រាក់ឈ្នួល។ ប្រសិនបើអ្នកជឿថាអ្នកត្រូវបានសងសឹក អ្នកគួរតែទាក់ទងទៅការិយាល័យគាំពារកម្មករតាមទូរស័ព្ទលេខ

## តើខ្ញុំដាក់ពាក្យបណ្តឹងដោយរបៀបណា?

**ទាក់ទងការិយាល័យការពារកម្មករតាមទូរស័ព្ទលេខ:**

- (215) 686-0802
- wagetheft@phila.gov
- phila.gov/labor
- 100 S Broad St - 4th Floor, Philadelphia PA 19102